# ទស្សនៈប្រធានវិស័យនិយម

(The subjectivism)


*ដោយៈ បណ្ឌិត* **ភ្គាន់ ធុល**

*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*

*វិទ្យាស្ថានមនុសាស្ត្រនិងវិទ្យាសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*


## ១- សេចក្តីផ្តើម

***វត្ថុទាំងឡាយ*** *នៅក្នុងធម្មជាតិ ឬក៏ហៅម្យ៉ាងទៀតថា* ***វត្ថុធម្មជាតិ*** (natural things) *ក៏បាន។ វត្ថុទាំងឡាយនេះសុទ្ធតែ មាន* ***គុណភាព*** (quality) *ផ្ទាល់របស់ពួកវា ប៉ុន្តែមនុស្សទាំងឡាយមានការយល់ដឹង អំពី* ***ទីតាំងគុណភាព*** (quality) *របស់ពួកវា មិនដូចគ្នាទេ។*

*អ្នកខ្លះយល់ឃើញថា* ***ទីតាំងនៃគុណភាពរបស់វត្ថុ*** *មាននៅក្នុងវត្ថុ។ ករណីដូចជា* ***សោភ័ណភាពរបស់ផ្កាមួយទង, ភាពរឹងរបស់ពេជ្រ, សេចក្តីរីករាយនៃ បទចម្រៀង*** *សុទ្ធតែជា* ***គុណភាពពិត*** *ដែលគេទាញបានមកពីផ្កា, មកពីពេជ្រ, និងមកពីបទចម្រៀងទាំងអស់។ នេះមានន័យថា ទីតាំងនៃគុណភាពរបស់វត្ថុមានពិតនៅក្នុងវត្ថុ ពោលគឺជាគុណភាពពិតរបស់វត្ថុនេះឯង។ ទស្សនៈដែលយល់ឃើញបែបនេះគេឱ្យឈ្មោះថា* ***ទស្សនៈវត្ថុវិស័យនិយម*** (objectivism)*។*

*ចំណែកឯអ្នកខ្លះទៀតយល់ឃើញផ្ទុយពីនេះថា* ***ទីតាំងនៃគុណភាពរបស់វត្ថុ*** *ពោលគឺ* ***សោភ័ណភាពរបស់ផ្កាមួយទង, ភាពរឹងរបស់ពេជ្រ*** *ជាដើម សុទ្ធតែមាន ទីតាំងនៅក្នុង****ចិត្តរបស់មនុស្ស*** (human mind)*។ នេះមានន័យថា ទីណាមានមនុស្ស ទីនោះក៏គេគិតថា* ***គុណភាពរបស់វត្ថុ*** *មាន អត្ថិភាពដែរ រីឯទីណាដែលគ្មានមនុស្ស ទី នោះក៏គេគិតថា* ***គុណភាពរបស់វត្ថុ*** *មិន មានអត្ថិភាព ដែរ។ ទស្សនៈដែលយល់ ឃើញបែបនេះ គេឱ្យឈ្មោះថា* ***ទស្សនៈប្រធានវិស័យនិយម*** (subjectivism)*។*

*ការជជែកវែកញែកសួរដេញដោលគ្នាពីរឿងរ៉ាវអំពី* ***ទីតាំងនៃគុណភាពរបស់ វត្ថុនេះ*** *កើតមានតាំងពីយូរយារមកហើយ គឺ តាំងពីសម័យផ្លេតូ* (Plato) *និងអារីស្តូតឹល* (Aristotle) *ដែលជាទស្សនវិទូក្រិកមកម៉្លេះ រហូតមកដល់ពេលសព្វថ្ងៃនេះក៏នៅតែ មានការជជែកគ្នាមិនទាន់ដាច់ស្រេចនៅ ឡើយទេ ដូចជាការជជែកគ្នាពីរឿង* ***លទ្ធិរូបធាតុនិយម*** (materialism) *របស់អារីស្តូតឹល និង* ***លទ្ធិមនោនិយម*** (idealism) *របស់ផ្លេតូដូច្នេះដែរ។*

បើមានការជជែកដោយខ្វែងគំនិតគ្នាបែបនេះ តើទីតាំងពិតនៃគុណភាពរបស់វត្ថុឋិតនៅទីណា ឋិតនៅក្នុង **វត្ថុ** (តាមទស្សនៈវត្ថុវិស័យនិយម) ឬក៏ឋិត នៅក្នុង **គំនិតមនុស្ស** (តាមទស្សនៈ ប្រធានវិស័យនិយម)?

រឿងនេះ ទោះជាវាមានទីតាំងឋិត នៅទីណាមួយក៏ដោយ ខ្ញុំទុកលទ្ធភាពឱ្យអ្នកដែលស្រលាញ់ចូលចិត្តគិត និងស្រាវជ្រាវទស្សនវិជ្ជាធ្វើការគិតដើម្បីស្វែងរក ចម្លើយដោយខ្លួនឯង។ នៅទីនេះ ខ្ញុំសុំ លើកយកតែ **ទស្សនៈប្រធានវិស័យនិយម** បកស្រាយតែប៉ុណ្ណោះ ចំណែកឯ **ទស្សនៈ វត្ថុវិស័យនិយម** លើកទៅសំណេរបន្ទាប់។ ខាងក្រោមនេះគឺជាគំនិតយល់ឃើញ និង ជាការបកស្រាយពី **ទីតាំងនៃ គុណភាពរបស់វត្ថុ** ដែលមានប្រភពនៅក្នុង **ចិត្តមនុស្ស** តាម **ទស្សនៈប្រធានវិស័យ និយម**។

## ២- ខ្លឹមសារ

**ទស្សនៈប្រធានវិស័យនិយម** ផ្សំឡើងពាក្យថា **ទស្សនៈ + ប្រធាន + វិស័យ + និយម**។ **ទស្សនៈ** គឺដំណើរយល់ឃើញ; **ប្រធាន** គឺ មេ ឬអ្នកដែលជាធំជាងគេ ដូច ជាប្រធានក្រុម, ប្រធានក្រុមប្រឹក្សា, មេគ្រួសារ, មេទ័ព; **វិស័យ** គឺ អារម្មណ៍, គំនិត, ទី, តំបន់, ទីបំផុត (នៃការមើលឃើញ) ករណីដូចជា ចក្ខុវិស័យ គឺជាទីបំផុត ឬចម្ងាយមួយដែលអាចក្រឡេកមើលទៅឃើញ, ចម្ងាយមួយបំផុតចុងភ្នែក; **និយម** គឺជាសេចក្ដីកំណត់, ធម្មតា, ធម្មជាតិ ឬ អនុលោមតាម, ការចូលចិត្តប្រកាន់យក ឬដើរតាម។

**ទស្សនៈប្រធានវិស័យនិយម** ឬ អាចហៅ បានម្យ៉ាងទៀតថា ទស្សនៈអត្តនោម័តិនិយម (= ទស្សនៈ + អត្តនោម័តិ + និយម)។ អត្តនោម័តិ (= អត្តនោ "នៃខ្លួន" + មតិ "គំនិត, ការយល់ឃើញ") គឺគំនិតនៃខ្លួន ឬការយល់ឃើញរបស់ខ្លួន; ការយល់ឃើញដោយគំនិតរបស់ខ្លួន[១]។

ទាំង **ទស្សនៈប្រធានវិស័យនិយម** និង **ទស្សនៈអត្តនោម័តិនិយម** មានអត្ថន័យជាភាសាអង់គ្លេសថា "subjectivism" ដែលមានន័យផ្ទុយគ្នាជាមួយនឹងពាក្យថា "objectivism"។ ពាក្យ subjectivism ទាញ ចេញមកពីពាក្យដើមថា subject (ប្រធាន) ដែលអាចបំបែកទៅជា subjection (ការដាក់ឱ្យនៅក្រោមអំណាច), subjective (តាមជំនឿ ឬគំនិតរបស់អ្នកណាម្នាក់), subjectivism (លទ្ធិអត្តនោម័តិនិយម), subjectivist (អ្នកអត្តនោម័តិនិយម), subjectivity (ប្រធានវិស័យភាព, អត្តនោ ម័តិ)។ បើនៅក្នុងសំណង់ប្រយោគភាសា អង់គ្លេស ដូចជា subject + Verb + object ... ពាក្យ subject មាន ន័យថា **ប្រធាន ប្រយោគ** ឬប្រធានកិរិយាស័ព្ទ មានន័យថា ជាអ្នកធ្វើអំពើទៅលើវត្ថុ ដែលគេ

---

[១] ជួនណាត "*វចនានុក្រមខ្មែរ* (អេឡិចត្រូនិច)," រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រ ទស្សនៈ, ប្រធាន, វិស័យ, និយម, អត្តនោម័តិ

ហៅថា កម្មបទ (object)។ បើប្រើផ្សំជាមួយពាក្យដទៃទៀត ដូចជា subject of discussion មានន័យថា ប្រធានបទពិភាក្សា, subject of investigation មានន័យថាកម្មវត្ថុ ពោល គឺអ្វីមួយដែលត្រូវគេលើកយកមកពិនិត្យ សង្កេត)។

ហេតុនេះ ទស្សនៈប្រធានវិស័យ និយម ឬទស្សនៈអត្តនោម័តិ មានន័យជា រួមថា គឺជា **ការយល់ឃើញទៅតាមគំនិតរបស់ខ្លួនឯង**។

គំនូសបំព្រួញអំពីប្រធានវិស័យនិយម

គំនិតមនុស្ស → វត្ថុ



នៅក្នុងទ្រឹស្តីពុទ្ធិ ឬពុទ្ធិវិទ្យា (epistmology) ទស្សនៈប្រធានវិស័យនិយម គឺ ជាទស្សនៈមួយដែលអះអាងថា **ពុទ្ធិ** របស់យើងចំពោះ **វត្ថុ** (object) ពោលគឺ **គុណភាព** (quality) **របស់វា** ហើយនិង ទំនាក់ទំនងអត្ថិភាពរវាង **វត្ថុ** និង **ប្រធាន វិស័យ** [មនុស្ស (knower)] មានទំនាក់ទំនងគ្នាទៅនឹង **ចិត្ត** (mind), **លក្ខខណ្ឌសរីរាង្គឥន្ទ្រិយ**(condition of sense organs) របស់យើង ក៏ដូចជា**កាលៈទេសៈ** (circumstances) ដែលនៅជុំវិញវត្ថុនោះ ដែរ។ កាលនិងលំហរបានធ្វើឱ្យ **សភាពខួរក្បាល** (the mental state) ហើយនិង **លក្ខខណ្ឌសរីរាង្គឥន្ទ្រិយ**[២] របស់មនុស្សដូចជា ភ្នែក (ចក្ខុន្ទ្រិយ), ត្រចៀក (សោតិន្ទ្រិយ) ច្រមុះ (ឃានិន្ទ្រិយ), អណ្តាត (ជីវ្ហិន្ទ្រិយ), កាយ (កាយិន្ទ្រិយ), មនោឬចិត្ត (មនិន្ទ្រិយ)[៣] ជាដើម ប្រែប្រួល នៅពេលនោះ **គំនិត** (ចិត្ត ឬ អារម្មណ៍) របស់យើងចំពោះ **គុណភាពរបស់វត្ថុ** ក៏នឹងប្រែប្រួលពី មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដែរ។ ជា ការពិត អ្នកជំងឺគ្រុនក្តៅ មានការយល់ដឹង ពីទ្រង់ទ្រាយនិងពណ៌វត្ថុជាក់ស្តែងខុសពី ការយល់ដឹងរបស់មនុស្សធម្មតា។ នៅ មានកត្តាក្រៅខ្លួន មនុស្សដទៃទៀតដូចជា **ពន្លឺ** (light) និង **ចម្ងាយ** (distance) ក៏មាន ឥទ្ធិពលទៅ លើការយល់ដឹងពីវត្ថុរបស់ គេដែរ។ ជាឧទាហរណ៍ **វត្ថុតែមួយ** អាច មានការយល់ឃើញខុសគ្នាពីមនុស្សម្នាក់ដែលឋិតនៅក្រោមពន្លឺព្រះអាទិត្យដ៏ភ្លឺចាំង និងមនុស្សម្នាក់ទៀតដែលឋិតនៅក្នុងបន្ទប់ងងឹត។ មានករណីដូចគ្នានេះដែរ មនុស្សម្នាក់មើលវត្ថុក្នុងចម្ងាយមួយម៉ែត្រ ឯមនុស្សម្នាក់ទៀតមើលវត្ថុក្នុងចម្ងាយ មួយពាន់ម៉ែត្រ[៤]។ កិច្ចសន្យាមួយមានអត្ថិភាពដោយសារតែសភាពចិត្តប្រែប្រួល។

ទ្រឹស្តីប្រធានវិស័យចំពោះពុទ្ធិនេះបានចាប់ផ្តើមតាំងពីសម័យសូក្រាជីស (the Socratic period) មកម្ល៉េះ គឺនៅពេល ដែលពួកសូហ្វីសវិទូ (sophist) ដែលជា ក្រុមទស្សនវិទូចំណាន។

[២] Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974 p.59

[៣] *ជួនណាត, ជ.ឯ.ម, ទំព័រ ឥន្ទ្រិយ*

[៤] Venancio B. Ardales, op. cit. p.59

និងជាទស្សនវិទូ ដំបូងគេគិតពីកម្រៃសម្រាប់ការអប់រំបាន បង្រៀនថា "មនុស្សគឺជារង្វាស់នៃគ្រប់ វត្ថុទាំងអស់ (man is the measure of all things)"។ ប្រូថាហ្គ័រាស (Protagoras) ជា សូហ្វីសវិទូល្បីល្បាញបានពោលថា ពុទ្ធិ មានទំនាក់ទំនងគ្នា ពោលគឺ វាគ្រាន់តែជាបញ្ហាមតិយោបល់ (a matter of opinion) ប៉ុណ្ណោះ។ ហេតុដូចនេះ មតិយោបល់ ពិសេសៗរបស់មនុស្សម្នាក់ៗមានលក្ខណៈត្រឹមត្រូវដោយឥតគិតថា តើវាអនុលោមទៅតាមមតិយោបល់របស់អ្នកដទៃដែរឬអត់ នោះទេ។ "អ្វីដែលត្រឹមត្រូវចំពោះអ្នកគឺវាត្រឹមត្រូវចំពោះអ្នក ហើយ អ្វីដែលត្រឹមត្រូវចំពោះខ្ញុំគឺ វាត្រឹមត្រូវ ចំពោះខ្ញុំ"។ ដូច្នេះ ប្រសិនបើរឿងនេះជា ករណីយមួយ (the case) នៅពេលនោះ **តថភាព** (reality) គឺពិតជាកើតឡើងដោយមនុស្ស ព្រោះថា បទពិសោធន៍ឥន្ទ្រិយ (sense experiences) របស់គេគឺជាការឆ្លុះបញ្ចាំងផ្ទាល់ពី **ពិភពខាងក្រៅ** (the external world)។ ហេតុដូច្នេះ តថភាព មិនមែនមានតែមួយ ប៉ុន្តែមានច្រើន គឺមាន ច្រើនទៅតាមចំនួនមនុស្ស ដែលយល់ដឹង ហើយនិងឆ្លុះបញ្ចាំងអំពីពិភពខាងក្រៅនោះដែរ[៥]។

មានមតិរិះគន់មួយប្រឆាំងទល់នឹងទ្រឹស្តីប្រធានវិស័យនេះ។ មតិរិះគន់នេះ បានលើកពីសំណួរថា តើគេអាចទុកចិត្ត លើប្រធានវិស័យក្នុងការវិនិច្ឆ័យដោយ ត្រឹមត្រូវពីគុណភាពពិតរបស់វត្ថុបានដែរ ឬទេ? ចម្លើយគឺថាទេ គេមិនអាចទុកចិត្តវា បានទេ ពីព្រោះថា សរីរាង្គឥន្ទ្រិយរបស់ យើងដែលបានផ្តល់ឱ្យយើងនូវទិន្នន័យថ្មីៗ (raw data) សម្រាប់ស្មារតីយកមកធ្វើ ការវិភាគ និងបកស្រាយពន្យល់នោះនៅ មិនទាន់សុក្រិតនៅឡើយទេ។ ជាញយៗ វាតែងកុហក់ ឬបោកបញ្ឆោតយើង។ ម្យ៉ាងទៀត ឥន្ទ្រិយពុទ្ធិ (sense perceptions) របស់យើងមិនអាចបុកទម្លាយចូលទៅ ផ្នែកខាងក្នុងរបស់វត្ថុបានឡើយ។ ដូច្នេះ ពុទ្ធិរបស់យើងនៅមានលក្ខណៈសើរៗ មិនស៊ីជម្រៅ (superficial) នៅឡើយទេ។ ដូច្នេះ គ្មានអ្នកណាម្នាក់ ហ៊ានអះអាងពីពុទ្ធិ ដាច់ខាត (absolute knowledge) របស់គេ បានឡើយ; ដោយហេតុថា អ្វីដែលគេ ស្គាល់នោះគឺវាទាក់ទងគ្នា និងត្រូវកំណត់ដោយ **បទពិសោធន៍** (experience) របស់យើងម្នាក់ៗ[៦]។

## ៣- បទពិសោធន៍

នៅក្នុងជីវភាពរស់នៅធម្មតា **បទពិសោធន៍** (experience) មានន័យថាគឺជាដំណើរការក្នុងការទទួលបាន **ចំណេះដឹង** (knowledge) ឬ **ជំនាញ** (skill) នៅក្នុងរយៈពេលមួយ តាមរយៈ **ការឃើញ**, ការមានវេទនារម្មណ៍, និង **ការធ្វើអ្វីៗ** ជាជាង តាមរយៈការ

[៥] Venancio B. Ardales, op. cit. p.59

[៦] Venancio B. Ardales, op. cit. p.60

សិក្សា[7]។

នៅក្នុងទស្សនវិជ្ជា **បទពិសោធន៍** ជាទូទៅគឺជាអ្វីដែលយើងយល់ឃើញតាមរយៈ អង្គវិញ្ញាណ (senses) ដែលយើងហៅថា **បទពិសោធន៍ឥន្ទ្រិយ** (sensory experience) ដែលជាអ្វីដែលយើងរៀនពី អ្នកដទៃ ឬជាអ្វីក៏ដោយដែលចេញមកពី ប្រភពខាងក្រៅ (external sources) ឬក៏ចេញមកពី **ការឆ្លុះបញ្ចាំងខាងក្នុង** (inner reflection)។ ក្នុងន័យនេះ **បទពិសោធន៍** ត្រូវបានគេផ្សារភ្ជាប់ជាមួយនឹង **ការសង្កេត** (observation) ហើយនិង **ការធ្វើពិសោធន៍** (experiment)។ **លទ្ធិពិសោធន៍និយម** (empiricism) សង្កត់ធ្ងន់ថា ចំណេះដឹងរបស់យើងត្រូវតែពឹងផ្អែកទៅលើ**បទពិសោធន៍** ប៉ុន្តែ **លទ្ធិសនិទាននិយម** (rationalism) អះអាងថា **បទពិសោធន៍** គឺជា **ប្រភពសក្តានុភូតនៃកំហុស** (potential source of error) ហើយវាបូលបិត្តភាព ប្រាកដប្រជាសនិទាន (rational certainty) ជាងទូទៅនិយកម្ម ដែលគ្រាន់តែជាពិសោធន៍ (mere empirical generaliza-tion)។ នៅក្នុងការប្រើប្រាស់ធម្មតា រាល់ បទពិសោធន៍ទាំងអស់សុទ្ធតែមានអ្វីមួយ ដែលមានបទពិសោធន៍ ដែលឯករាជ្យពី ប្រធានបទនៃបទពិសោធន៍ (subject of experience)។ ប៉ុន្តែ នៅក្នុងទស្សនវិជ្ជា ទំនាក់ទំនងរវាង **បទពិសោធន៍** ដែលជាសភាពនៃសេចក្តីដឹង (a state of cons-ciousness) និងវត្ថុឯករាជ្យពី បទពិសោធន៍ (independent objects of experience) បានក្លាយទៅជាចំណុចផ្តោតមួយ នៅក្នុងការពិភាក្សាគ្នា។ វាត្រូវតែមានអ្វីមួយ ដែល គេបានផ្តល់ឱ្យនៅក្នុងបទពិសោធន៍ ប៉ុន្តែ សភាពនៃអ្វី ដែលគេបានផ្តល់ឱ្យនោះ គឺ មានភាពចម្រូងចម្រាសខ្លាំងណាស់។ ចម្លើយផ្សេងៗគ្នា គឺអាស្រ័យទៅលើ គោលជំហរដូចជា **លទ្ធិតថនិយម** (realism), **លទ្ធិមនោនិយម** (idealism), និង **លទ្ធិមជ្ឈជាតុនិយម** (skepticism)។ មានវិធីយល់ដឹងពីអ្វីដែលគេបានផ្តល់ឱ្យ ផ្សេងៗពីគ្នា ហើយក៏ជាប់ពាក់ព័ន្ធទៅនឹង វិធីយល់ដឹងពីសញ្ញាណទិន្នន័យឥន្ទ្រិយ (sense-data) ខុសៗគ្នាផងដែរ។ វាក៏មាន ការជជែកវែកញែកអំពីទំនាក់ទំនងរវាង **បទពិសោធន៍** និង **ទ្រឹស្តី** ផងដែរ។ ចាប់ផ្តើម ដោយខាន្ត(Kant) គឺថា មានទំនោរមួយក្នុង ការបដិសេធពីរឿងរ៉ាវបទពិសោធន៍ ដែលជាឥន្ទ្រិយារម្មណ៍ សុទ្ធសាធដែលមិនដំណើរការដោយគំនិត។ នៅក្នុងទស្សនវិជ្ជាចិត្ត ទំនើប មានប្រធានបទសំខាន់មួយ ដែលទាក់ទងទៅនឹងបញ្ហាទ្រឹស្តីជាច្រើន ទាក់ទងទៅនឹងឯកជនភាពដែលគេពោលអះអាងពីបទពិសោធន៍មួយ ដែលជាព្រឹត្តិការណ៍មួយដែលអាចដឹងបានតែចំពោះម្ចាស់របស់វា ហើយនិងលទ្ធភាពចូលទៅ

[៧] Jonathan Crowther, *"Oxford Advanced Learner's Dictionary of Current English,"* 5th ed. Oxford university press, 1995 p.404

ដល់បទពិសោធន៍នោះជាសាធារណៈ[៨]។

នៅចុងចំណុចទី២អំពីខ្លឹមសារ ប្រធាន វិស័យ មានមតិរិះគន់មួយបាន ចោទសួរថា តើគេអាចទុកចិត្តលើប្រធាន វិស័យក្នុងការ វិនិច្ឆ័យដោយត្រឹមត្រូវពី **គុណភាពពិតរបស់វត្ថុ** បានដែរឬទេនោះ មានចម្លើយមួយឆ្លើយតប ទៅនឹងការចោទសួរនោះថា គេមិនអាចទុកចិត្ត លើវាបានទេ ពីព្រោះថា អ្វីដែលគេស្គាល់ នោះគឺវាទាក់ ទងគ្នានិងត្រូវកំណត់ដោយ **បទពិសោធន៍** (experience) របស់យើងម្នាក់ៗ។ នៅក្នុង ន័យនេះ **បទពិសោធន៍** គឺជា **គុណភាព** ឬ ជា **សមត្ថភាពយល់ដឹងរបស់ប្រធាន វិស័យ** ក្នុងការស្វែងរក **សច្ចភាពពីគុណ ភាពពិតរបស់វត្ថុ** (the truth of true quality of things)។ **ប្រធាន វិស័យ** (មនុស្ស) មាន **បទពិសោធន៍** មិនដូចគ្នាទេ។ **ប្រធាន វិស័យខ្លះ** មាន **បទពិសោធន៍** កាន់តែច្រើន ការស្វែងរកសច្ចភាពក៏កាន់តែ សុក្រិត ដែលអាចឱ្យគេទុកចិត្តនិងជឿជាក់បាន កាន់តែច្រើនដែរ។ ផ្ទុយទៅវិញ ប្រធាន វិស័យ ខ្លះមាន **បទពិសោធន៍ច្រើន** ពិតមែន តែការ ស្វែងរកសច្ចភាពរបស់គេនៅមាន កម្រិត មិន ស៊ីជម្រៅ អសុក្រិត ដែលមិន អាចឱ្យគេជឿទុក ចិត្តបានឡើយ។ ឯប្រធាន វិស័យខ្លះទៀតមាន **បទពិសោធន៍តិច** តែ គុណភាព ឬ សមត្ថភាព យល់ដឹងរបស់ ពួកគេល្អ និងស៊ីជម្រៅ ហើយប្រសិនបើ ប្រធានវិស័យទាំងអស់ នោះមាន **បទពិសោធន៍** កាន់តែច្រើនទៀត គុណភាព ឬសមត្ថភាពយល់ដឹងរបស់ពួកគេ ក៏កាន់ តែល្អ និងស៊ីជម្រៅដែរ។ រឿងនេះ អាស្រ័យទៅលើសំណុំប្រព័ន្ធគិតរបស់ ពួកគេ មានគុណភាពល្អ។ ឧទាហរណ៍ អ្នកខ្លះអាចគិត បានរយៈពេលតែ១ម៉ោង ឬ ២ម៉ោង។ ឯអ្នកខ្លះ ទៀតបានរយៈពេល៨ ទៅ១០ម៉ោង។ ចំពោះ ប្រធានវិស័យដែល មានសំណុំប្រព័ន្ធគិតល្អ មែនទែន អាចមាន សមត្ថភាពធ្វើការងារស្ទើរ គ្រប់២៤ម៉ោង ពេញ គឺសម្រាកតែ១ម៉ោង ប៉ុណ្ណោះ។ ប្រធានវិស័យដែលខ្ញុំចង់សំដៅដល់ នៅទី នេះ គឺជា **ព្រះពុទ្ធ**។

ព្រះពុទ្ធអង្គតែងបំពេញពុទ្ធកិច្ច៥ ប្រការជានិច្ចអស់រយៈពេល៤៥វស្សា។

**កិច្ចការទី១នៅពេលព្រឹក** (ពីម៉ោង ៤.០០ ដល់ម៉ោង១២.០០ថ្ងៃត្រង់) ព្រះពុទ្ធ ទ្រង់ក្រោកពីសឹងនៅម៉ោង៤.០០ ហើយ ទ្រង់ក៏ លុបលាងព្រះកាយ បន្ទាប់មកទ្រង់ ក៏គង់ធ្វើ សមាធិរយៈពេលមួយម៉ោង។ បន្ទាប់មក ចាប់ ពីម៉ោង៥.០០ដល់ ម៉ោង ៦.០០ ទ្រង់ទតមើល ជុំវិញពិភពលោក ដោយចក្ខុញាណ (mental eye) ដើម្បី ប្រមើលមើលពីអ្នកដែលទ្រង់អាច ជួយ បាន។ នៅម៉ោង៦.០០ ទ្រង់គ្រងស្បង់ចីវរ ដើម្បីយាងទៅបិណ្ឌបាត្រនៅតាមភូមិ ឬ នៅតាមទីក្រុងជិតៗដែលទ្រង់កំពុងគង់ នៅ ឬប្រសិនបើមានអ្នកណាចង់ឱ្យព្រះ អង្គជួយជា

---

[៨] Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004 p.240

បន្ទាន់ ទ្រង់ក៏យាងទៅទីនោះ ភ្លាមជាមួយនឹងសង្ឃដទៃ ឬក៏ទ្រង់យាង ទៅតែមួយព្រះអង្គឯង។ បន្ទាប់មកទៀត ទ្រង់យាងពីផ្ទះមួយទៅផ្ទះមួយដោយព្រះ នេត្ររបស់ទ្រង់រំពៃមើលមិនដាក់ទៅលើដី ពីព្រោះ ខ្លាចជាន់ត្រូវសត្វផ្សេងៗ។ ព្រះ អង្គទទួលយកចង្ហាន់ដែលគេប្រគេនព្រះ អង្គដោយស្ងៀមស្ងាត់។ ប្រសិនបើព្រះអង្គ គង់នៅជាមួយសាវ័ក ព្រះអង្គយាងទៅបិណ្ឌបាត្រជាមួយសាវ័កទាំងនោះ ដោយនិមន្តជាជួរតែមួយពីក្រោយព្រះអង្គ។ ប្រសិនបើមានមនុស្សម្នា និមន្តព្រះអង្គទៅ ផ្ទះរបស់គេដើម្បីឆាន់ចង្ហាន់ថ្ងៃត្រង់ ព្រះ អង្គក៏និមន្តទៅទីនោះ។ បន្ទាប់ពីចង្ហាន់ត្រង់ ហើយព្រះអង្គសម្តែងធម្មទេសនាដល់ ប្រជានិករនិងព្រះសង្ឃអំពី ***អរិយសច្ចៈ*** របស់ព្រះអង្គ។ ប្រសិនបើមានអ្នកណា ចង់ឱ្យព្រះអង្គបំបួសព្រះអង្គក៏បំបួសអ្នក នោះ។

***កិច្ចការទី២នៅពេលរសៀល៖*** (ចាប់ពីម៉ោង១២.០០ដល់ម៉ោង៦.០០ ល្ងាច) នេះជាពេលដែលតាមធម្មតា ព្រះ សង្ឃនិមន្តចូលមកគាល់ព្រះពុទ្ធ ដើម្បីសួរ សំណួរដល់ព្រះអង្គ។ ប្រសិនបើមាន សំណួរវិញ ព្រះអង្គឆ្លើយនិងដោះស្រាយ វាហើយប្រទានដំបូន្មានដល់ពួកសង្ឃ ហើយនិងប្រធានបទសម្រាប់ចម្រើនភាវនា។ នៅពេលពួកសង្ឃនិមន្តចេញទៅ ព្រះអង្គសំរាកនៅក្នុងបន្ទប់ព្រះអង្គ ហើយ ទ្រង់ទតមើលជុំវិញពិភពលោកដោយចក្ខុញាណរបស់ទ្រង់ថា តើមានសត្វលោក ណាត្រូវការឱ្យព្រះអង្គជួយដែរឬទេ។ ប្រសិនបើព្រះអង្គរកឃើញ ទ្រង់ក៏និមន្ត ទៅទីនោះ។ ឬប្រសិនបើគ្មានទេ ទ្រង់និមន្ត មកខាងក្រៅបន្ទប់ ដើម្បីជួបជាមួយ មនុស្សរាប់រយនាក់ ដែលកំពុងរង់ចាំស្តាប់ ធម្មទេសនារបស់ព្រះអង្គ។

***ការប្រមើលមើលលើកទី១*** (ពីម៉ោង ៦.០០ ដល់ ១០.០០ ល្ងាច) អំឡុងពេលនេះ ព្រះសង្ឃនិមន្តមកម្តងទៀត ដើម្បីស្តាប់ ធម្មទេសនា និងសួរសំណួរចំពោះសេចក្តី មន្ទិលសង្ស័យរបស់ពួកគេឱ្យច្បាស់ លាស់។ មនុស្សម្នាមកគាល់ព្រះពុទ្ធនៅ ពេលនេះនៅពេលយប់។

***ការប្រមើលមើលលើកទី២*** (១០.០០ យប់-២.០០ព្រឹក) អំឡុងពេលនេះ ទេពតាយាងមកគាល់ព្រះពុទ្ធ និងសិក្សាពីសច្ច ធម៌នៃជីវិតរបស់ទ្រង់ យើងមិនអាចមើលឃើញដោយភ្នែកទទេបានទេ។

***ការប្រមើលមើលលើកចុងក្រោយ*** (២.០០-៤.០០ព្រឹក) ពីម៉ោង២ដល់ម៉ោង៣ ទ្រង់និមន្តចុះឡើងៗ។ ***ពីម៉ោង៣ដល់ម៉ោង៤ព្រះពុទ្ធផ្ទំ***។ បន្ទាប់មកទ្រង់ក៏ក្រោក ហើយបន្តការងាររបស់ព្រះអង្គទៅតាម លំដាប់តទៅទៀត[៥]។

ដូចនេះយើងឃើញថា ព្រះពុទ្ធរវល់ពេញមួយថ្ងៃ។ តាមពិត ព្រះពុទ្ធផ្ទំតែមួយម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃអស់រយៈពេល

---

[៥] Rev. Siridhama, *the life of the Buddha*, Taiwan,1995, p72-73

៤៥ឆ្នាំក្នុងភាពជាព្រះពុទ្ធ។ អំឡុងពេលថ្ងៃដំបូង ព្រះអង្គទ្រង់ទតឃើញពិភពលោកទាំងមូល និងសុំឱ្យពិភពលោកទាំងមូល ប្រកបដោយសេចក្តីស្រលាញ់គ្មានទីបញ្ចប់របស់ទ្រង់ផង និងនាំមកនូវភាពសប្បាយ រីករាយដល់មនុស្សរាប់លាននាក់ផង។

## សេចក្តីសន្និដ្ឋាន

ប្រធានវិស័យមានកម្រិតទាបខ្ពស់ មិនដូចគ្នាទេ។ កត្តាដែលធ្វើឱ្យវាមិនអាចដូចគ្នានេះ គឺវាទាក់ទងជាសំខាន់ទៅលើ **បទពិសោធន៍តិចឬច្រើន** និង **គុណភាពនៃសំណុំប្រព័ន្ធគិត** របស់គេ។ នៅក្នុងកំណត់ត្រាប្រវត្តិទស្សនវិជ្ជាក្រិកបុរាណបង្ហាញ ថា ទស្សនវិទូសម័យដើមមានការយល់ ខុសទៅលើទម្រង់ ហើយនិងទំហំផែនដី។ **សេលីស** [Thales (៦២៤-៥៤៧ មុន គ.ស.)] ជាទស្សនវិទូ, គណិតវិទូ, និងជាតារាវិទូដំបូងរបស់ក្រិក។ នៅក្នុងការស្រាវជ្រាវអំពីផែនដី លោកយល់ថា ផែនដីប្រៀបដូចជាថាសធំសម្បើមមួយ ដែលអណ្តែតលើផ្ទៃទឹក។ លោកយល់ថា **ការញ្ជួយផែនដី** គឺជាការប៉ះទង្គិចយ៉ាង ខ្លាំងរវាងផែនដីនិងព្យុះរលកសមុទ្រ។ ការប៉ះទង្គិចនោះប្រៀបដូចជាការប៉ះ ទង្គិចនៃ កប៉ាល់មួយនៅលើទឹក ដែលមានរលក ខ្លាំង។ ការពន្យល់បែបនេះធ្វើឱ្យមនុស្ស សម័យនោះមានការយល់ស្របដោយខុសជាច្រើន។ ការអនុញ្ញាតឱ្យ **មតិភាគច្រើន** ឬមនុស្សគ្រប់រូបធ្វើការសម្រេចចិត្តទៅ លើ **បញ្ហាវិទ្យាសាស្ត្រ** នៅពេលដែលពួក គេមិនមែនជា **អ្នកវិទ្យាសាស្ត្រ** ដែលមិន ធ្លាប់បានទទួលនូវការ ហ្វឹកហាត់វិទ្យាសាស្ត្រ ផងនោះ គឺជាការខុសឆ្គង ហើយគេមិនអាចយកជាការបានទេ។

ហេតុនេះប្រធានវិស័យទាមទាឱ្យមានបទពិសោធន៍ច្រើន កាន់តែច្រើនកាន់តែល្អ ដើម្បីដឹកនាំការងារនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ មិនថានៅក្នុងគ្រួសារ, សាលារៀន, ឬស្ថាប័នរដ្ឋ ឱ្យមានសេចក្តីសុខនិងសេចក្តីចម្រើន។

## គន្ថនិទ្ទេស


### I- ស្នាដៃនិពន្ធជាភាសាខ្មែរ

១- ជួនណាត, *វចនានុក្រមខ្មែរ* (អេឡិចត្រូនិច), រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨។

### II- ស្នាដៃនិពន្ធជាភាសាអង់គ្លេស

1- Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974

2- Jonathan Crowther, *"Oxford Advanced Learner's Dictionary of Current English,"* 5th ed. Oxford university press, 1995

3- Nicholas Bunnin And Jiyuan Yu,

.

*The Blackwell Dictionary of Western Philosophy*, USA, First published, 2004

4- Rev. Siridhama, *the life of the Buddha*, Taiwan,1995